# ថ្នាំបង្ការ

## សម្រាប់អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ

ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយ អ្នកអាចនឹងមានការពិបាកច្រើនជាងមុនក្នុងការការពារខ្លួនអ្នកផ្ទាល់ប្រឆាំងនឹងជំងឺផ្សេងៗណាដែលអាចទប់ស្កាត់បាន។ ជំងឺមួយចំនួនដែលអាចទប់ស្កាត់បានដោយថ្នាំបង្ការអាចធ្វើឱ្យអ្នកប្រឈមនឹងហានិភ័យខ្ពស់ជាងមុននៃការឆ្លងមេរោគកម្រិតធ្ងន់ធ្ងរទៅក្នុងស្ថានភាពដែលអាចនឹងតម្រូវចាំបាច់ត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬសូម្បីតែបណ្តាលឱ្យស្លាប់ទៀតផង។



ការចាក់ថ្នាំបង្ការគឺជាវិធីដែលមានសុវត្ថិភាព មានប្រសិទ្ធិភាព និងមានភាពងាយស្រួលមួយដើម្បីការពារខ្លួនអ្នកផ្ទាល់ប្រឆាំងនឹងជំងឺផ្សេងៗណាដែលអាចទប់ស្កាត់បាន។ ថ្នាំបង្ការទាំងឡាយគឺសំខាន់ជាពិសេសសម្រាប់អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ ពីព្រោះអ្នកមានការពិបាកច្រើនជាងមុនក្នុងការជាសះស្បើយឡើងវិញពីការឆ្លងមេរោគ ឬពីជំងឺផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ អាស្រ័យទៅលើថាតើមានការប៉ះពាល់ទៅលើប្រព័ន្ធភាពស៊ាំរបស់អ្នកដល់កម្រិតណានោះ អ្នកអាចនឹងត្រូវការជៀសវាងចាក់ថ្នាំបង្ការជាក់លាក់ផ្សេងៗ ឬរង់ចាំរហូតដល់ប្រព័ន្ធភាពស៊ាំរបស់អ្នកបានរឹងមាំជាងមុនសិន។

សូមសាកសួរទៅកាន់អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកថាតើថ្នាំបង្ការណាខ្លះដែលមានការណែនាំសម្រាប់ឱ្យអ្នកទទួលចាក់។

### តើខ្ញុំត្រូវការចាក់ថ្នាំបង្ការណាខ្លះ?

- **ថ្នាំបង្ការជំងឺ COVID-19៖** យូរៗម្តង មានការធ្វើឱ្យថ្នាំបង្ការនេះបានថ្មីឡើងវិញ ដើម្បីប្រឆាំងនឹងពូជថ្មីបំផុតរបស់មេរោគ។ មានការណែនាំឱ្យមនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ ទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated COVID-19 vaccine) យ៉ាងហោចណាស់ចំនួន 1 ដូស។ អ្នកដែលមាន ប្រព័ន្ធភាពស៊ាំចុះខ្សោយ អាចនឹងត្រូវទទួលចាក់ដូសថ្នាំបង្ការជំងឺ COVID-19 សម្រាប់ឆ្នាំ 2023-2024 បន្ថែមទៀត។

  អ្នកដែលមិនបានចាក់ថ្នាំបង្ការពីពេលកន្លងមក គួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ mRNA (ប្រភេទ Pfizer-BioNTech ឬប្រភេទ Moderna) ដែលបានធ្វើឱ្យថ្មីឡើងវិញចំនួន 3 ដូស ឬក៏ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Novavax ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated Novavax COVID-19 vaccine) ចំនួន 2 ដូស។

  អ្នកដែលបានចាក់ថ្នាំបង្ការប្រភេទ Novavax ដើម ឬក៏ថ្នាំបង្ការប្រភេទ mRNA បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន (monovalent) ឬបែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន (bivalent) ពីពេលកន្លងមក ត្រូវការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញចំនួន 1 ឬ 2 ដូស អាស្រ័យទៅលើចំនួនដូសដែលបានទទួលចាក់ពីពេលមុនមក។

- **ថ្នាំបង្ការជំងឺគ្រុនផ្តាសាយធំ (Flu)៖** អ្នកគួរតែទទួលចាក់ថ្នាំបង្ការនេះជារៀងរាល់ឆ្នាំ ជាពិសេសនៅរដូវស្លឹកឈើជ្រុះ ដើម្បីកាត់បន្ថយហានិភ័យនៃការកើតជំងឺគ្រុនផ្តាសាយធំ។ ប្រសិនបើអ្នក មានអាយុចាប់ពី 65 ឆ្នាំឡើងទៅ សូមសាកសួរទៅកាន់អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកអំពីថ្នាំបង្ការជំងឺគ្រុនផ្តាសាយធំដែលមានកម្រិតដូសខ្ពស់ជាងមុន។

# ថ្នាំបង្ការ
## សម្រាប់អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ

- **សម្រាប់ RSV៖** ចំពោះអ្នកដែលមានអាយុចាប់ពី 60 ឆ្នាំឡើងទៅ ថ្នាំបង្ការសម្រាប់ RSV ចំនួនមួយដូស ការពារប្រឆាំងនឹងជំងឺកម្រិតធ្ងន់ធ្ងរបង្កឡើងដោយមេរោគប្រភេទ syncytial ដែលឆ្លងតាមផ្លូវដង្ហើមរបស់មនុស្ស (respiratory syncytial virus/RSV) ហើយដែលបណ្តាលឱ្យមានការឆ្លងមេរោគទៅក្នុងសួតចំពោះបុគ្គលទាំងឡាយដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ។

  ទារកដែលមានអាយុក្រោម 8 ខែគួរតែទទួលចាក់ថ្នាំប្រភេទ nirsevimab (ម៉ាក Beyfortus) ចំនួនមួយដូស មុនពេលឬក្នុងអំឡុងពេលរដូវកាលមាន RSV ច្រើន (ចាប់ពីខែតុលា ដល់ខែមីនា) ដើម្បីការពារពួកគេពីការឆ្លងមេរោគទៅក្នុងសួត។ ទារក និងកុមារដែលមានអាយុចាប់ពី 8 ទៅ 19 ខែ ហើយដែលប្រឈមនឹងហានិភ័យខ្ពស់ក្នុងការមានជំងឺដែលកើតពី RSV កម្រិតធ្ងន់ធ្ងរ និងកំពុងឈានចូលរដូវកាលមាន RSV ច្រើនទីពីររបស់ពួកគេក៏គួរតែទទួលចាក់ថ្នាំប្រភេទ nirsevimab ចំនួនមួយដូសផងដែរ។

- **ថ្នាំបង្ការជំងឺរលាកសួត (Pneumonia)៖** ការពារប្រឆាំងនឹងមេរោគ pneumococcal ជាច្រើនប្រភេទ ដែលអាចបណ្តាលឱ្យមានការឆ្លងមេរោគកម្រិតធ្ងន់ធ្ងរដល់កុមារ និងមនុស្សពេញវ័យ។ មានការណែនាំឱ្យទទួលចាក់លំដាប់ថ្នាំបង្ការសម្រាប់ពេលកុមារភាពដែលមានចំនួន 4 ដូសនេះ មុនពេលមានអាយុ 5 ឆ្នាំ។ ដំបូន្មានទាំងឡាយសម្រាប់កុមារធំៗ និងមនុស្សពេញវ័យអាចនឹងទទួលបាន នៅទីនេះ។

## តើខ្ញុំទទួលចាក់ថ្នាំបង្ការបានយ៉ាងដូចម្តេចខ្លះ?



- ❖ ទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ឬឱសថស្ថាន (កន្លែងលក់ថ្នាំពេទ្យ) របស់អ្នក។
- ❖ សាកសួរទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកថាតើមានការណែនាំឱ្យអ្នកទទួលចាក់ដូសបន្ថែមទៀតឬទេ។
- ❖ ប្រសិនបើអ្នកមិនមានអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពប្រចាំខ្លួនទេនោះ សូមចូលទៅកាន់គេហទំព័រ http://publichealth.lacounty.gov/vaccines សម្រាប់បញ្ជីឈ្មោះគ្លីនិកដែលផ្តល់ការចាក់ថ្នាំបង្ការជូនដោយមិនគិតថ្លៃ ឬគិតថ្លៃទាប ហើយនិងព័ត៌មានបន្ថែមទៀតអំពីថ្នាំបង្ការទាំងឡាយ។
- ❖ ចំណុចល្អបំផុតនោះគឺថាអ្នកអាចទទួលចាក់ថ្នាំបង្ការភាគច្រើនក្នុងពេលតំណាលគ្នាបាន!

**សម្រាប់បញ្ជីថ្នាំបង្ការដែលមានការណែនាំឱ្យទទួលចាក់ សូមចូលទៅកាន់គេហទំព័រ៖ www.cdc.gov/vaccines។**



### មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health Call Center)

សម្រាប់ព័ត៌មានបន្ថែម មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈមានបម្រើសេវាកម្មជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈលេខ **1-833-540-0473**។